ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ ៧.០៩១..ន.ទ.ក.

# សេចក្តីប្រកាសព័ត៌មាន

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ន.ទ.ក. ក្នុងកិច្ចសហការជាមួយអគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចុះបង្ក្រាបការលួចស្ទាបនាបណ្តាញខ្សែកាប្លិ៍អុបទិករបស់ក្រុមហ៊ុន**ស្មាត អាស្យាតា ខូអិលធីឌី** ដែលតួលេខបឋមមានប្រវែងប្រមាណ១៦គីឡូម៉ែត្រ ដែលស្ថិតនៅទីតាំងបីផ្សេងគ្នាគឺ (១) ភូមិត្រពាំងសាប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ (២) ភូមិត្រពាំងលៀន ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ និង (៣) ភូមិត្រាំខ្នារ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ហើយជាលទ្ធផលគឺបានរឹបអូសរាល់វត្ថុតាងយកមករក្សាទុក ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់និងឈានទៅដល់ការឃាត់ខ្លួនបុគ្គលពាក់ព័ន្ធមួយចំនួននិងបណ្តឹងប្រឆាំងទៅនឹងក្រុមហ៊ុន**ស្មាត អាស្យាតា ខូអិលធីឌី** ផងដែរ។ ទន្ទឹមនឹងការបង្ក្រាបនេះ ន.ទ.ក. នឹងបន្តចុះត្រួតពិនិត្យរាល់ការស្ទាបនាបណ្តាញខ្សែកាប្លិ៍អុបទិកនានាទាំងឡាយ នៅទូទាំងប្រទេសជាបន្តបន្ទាប់ទៀត ដើម្បីធានាថាការស្ទាបនាទាំងនោះ ប្រព្រឹត្តិទៅប្រកបដោយអនុលោមភាពគតិយុត្តនិងបច្ចេកទេស។

ជានិច្ចកាល ន.ទ.ក. តែងតែជូនដំណឹងនិងណែនាំដល់ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ឱ្យយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់ឱ្យបានខ្ជាប់ខ្ជួន។ ក៏ប៉ុន្តែប្រតិបត្តិករទូរគមនាគមន៍មួយចំនួន នៅតែបន្តបំពានច្បាប់យ៉ាងគឃ្លើន ជាក់ស្តែងករណីក្រុមហ៊ុន**ស្មាត អាស្យាតា ខូអិលធីឌី** ដែលត្រូវបានបង្ក្រាបនៅថ្ងៃនេះជាដើម។

ន.ទ.ក. សូមអំពាវនាវសាជាថ្មីដល់ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ឱ្យគោរពច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធព្រមទាំងពិនិត្យលក្ខខណ្ឌ ដែលមានចែងក្នុងអាជ្ញាបណ្ណ ឱ្យបានត្រឹមត្រូវនៅមុនធ្វើសកម្មភាពណាមួយ ហើយក្នុងករណីមានភាពស្រពេចស្រពិល អាចស្នើសុំការណែនាំពី ន.ទ.ក. បានគ្រប់ពេល ក្នុងន័យរួមគ្នាលើកកម្ពស់ការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវនិងអនុវត្តទៅតាមលក្ខខណ្ឌអាជ្ញាបណ្ណ ដែលក្រុមហ៊ុនទទួលបាន ចៀសវាងការបំពានទៅដល់អាជ្ញាបណ្ណរបស់ប្រតិបត្តិករដ៏ទៃទៀតនិងធានាបានថាប្រព័ន្ធទូរគមនាគមន៍ មានដំណើរការល្អប្រសើរ ដើម្បីបម្រើសេចក្តីត្រូវការជូនដល់សាធារណជន។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh